លេខចេញផ្សាយទី៦ ខែវិច្ឆិកា ២០២០

## មាតិកា

១. ទស្សនៈពីអ្នកទទួលផលនៅក្នុងគម្រោង លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន
២. ឯកសារណែនាំត្រូវបានបោះពុម្ពផ្សាយ
៣. ថ្លែងអំណរគុណចំពោះម្ចាស់ជំនួយ
៤. ព័ត៌មានទំនាក់ទំនង

# TIGER

លើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន

TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

## ទស្សនៈពីអ្នកទទួលផលនៅក្នុងគម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន

គម្រោងលើកកម្ពស់ការឆ្លើយតបនឹងសមភាពយេនឌ័រក្នុងការបង្រៀន និងរៀន (TIGER) គឺជាជោគជ័យមួយ ដោយសារមានគំរូយេនឌ័រ និងអ្នកដែលធ្វើឱ្យមានការផ្លាស់ប្តូរផ្នែកយេនឌ័រជាច្រើនបានចូលរួមក្នុងគម្រោងនេះ។ ខណៈពេលដែលគម្រោងខិតជិតដល់ទីបញ្ចប់ ពួកយើងមានមោទនភាពក្នុងការចែករំលែកដំណើររឿងអំពីការផ្លាស់ប្តូររបស់បុគ្គលសំខាន់១៦រូប តាមរយៈគម្រោង TIGER ។

សាច់រឿងអំពីការផ្លាស់ប្តូរទាំងស្រុងគឺមាននៅគេហទំព័រ YouTube របស់អង្គការ វីវីអូប៊ី។



**កញ្ញា ទេព វណ្ណី ជានាយិការងនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង បានមានប្រសាសន៍ថា៖** *"ខ្ញុំជឿជាក់ថា ដោយសារការអនុវត្តគម្រោង TIGER គរុសិស្សដែលនឹងក្លាយជាគ្រូបង្រៀននឹងបន្តអនុវត្តសកម្មភាពឆ្លើយតបនឹងសមភាពយេនឌ័រដោយប្រើកិច្ចតែងការ និងវិធីសាស្រ្តបង្រៀនដែលយើងបានបង្រៀនពួកគេ ហើយលោកគ្រូ អ្នកគ្រូទាំងនេះនឹងអប់រំសិស្សជំនាន់ក្រោយឱ្យមានការឆ្លើយតបនឹងយេនឌ័រ"។*



**លោកស្រី យិន អន ជានាយិការងនៃសាលាបឋមសិក្សាអន្លង់វិល បានមានប្រសាសន៍ថា៖** *"ខ្ញុំបានអនុវត្តជាក់ស្តែងនៅក្នុងសាលារៀនរបស់ខ្ញុំ នូវអ្វីដែលខ្ញុំរៀនចេះក្នុងអំឡុងពេលអនុវត្តគម្រោង។ ឧទាហរណ៍៖ ខ្ញុំបានពិនិត្យ កិច្ចតែងការបង្រៀនរបស់គ្រូដើម្បីបញ្ជាក់ថាតើគាត់បានបញ្ចូលខ្លឹមសារពាក់ព័ន្ធនឹងសមភាពយេនឌ័រនៅក្នុងវត្ថុបំណងមេរៀនហើយឬនៅ ហើយដើម្បីធានាថាគាត់បានអនុវត្តនូវអ្វីដែលបានសរសេរនៅក្នុងកិច្ចតែងការបង្រៀន ខ្ញុំក៏បានសង្កេតការបង្រៀនជាក់ស្តែងដែរ"។*



**លោក យ៉ុន សុខហេង ជាគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង បានមានប្រសាសន៍ថា៖** *"ចាប់តាំងពីខ្ញុំបានចូលរួមក្នុងគម្រោងនេះមក ខ្ញុំចាប់ផ្តើមធ្វើការស្វ័យឆ្លុះបញ្ចាំង។ ខ្ញុំស្វែងយល់ឃើញថា គោលការណ៍ដែលខ្ញុំបានប្រើប្រាស់សម្រាប់បង្រៀនសិស្សកន្លងមក មានផលប៉ះពាល់អវិជ្ជមានដល់អារម្មណ៍របស់ពួកគេ។ ដូច្នេះ ខ្ញុំបានផ្លាស់ប្តូរការបង្រៀនរបស់ខ្ញុំ"។*



**លោក រឿត បូរ ជាគ្រូបង្រៀនមុខវិជ្ជារូបវិទ្យា និងគីមីវិទ្យានៅអនុវិទ្យាល័យសោហី បានមានប្រសាសន៍ថា៖** *"ខ្ញុំបានចាប់ផ្តើមអនុវត្តសមភាពយេនឌ័រនៅក្នុងកិច្ចតែងការបង្រៀនរបស់ខ្ញុំ ដូចជារៀបចំឱ្យមានការចូលរួមស្មើគ្នារវាងសិស្សប្រុស និងសិស្សស្រី។ ប្រសិនបើសិស្សប្រុសឆ្លើយសំណួរដំបូង ខ្ញុំនឹងផ្តល់ឱកាសឱ្យសិស្សស្រីឆ្លើយសំណួរបន្ទាប់"។*



**លោក ផុន វណ្ណៈ ជាគរុសិស្សឆ្នាំទី២នៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង បានមានប្រសាសន៍ថា៖** *"នៅវិទ្យាស្ថានគរុកោសល្យ លោកគ្រូ អ្នកគ្រូតែងតែបែងចែងក្រុមឱ្យមានលក្ខណៈ ចម្រុះ។ ឧទាហរណ៍ដូចជាមានទាំងគរុសិស្សប្រុស និងគរុសិស្សស្រី ហើយមានទាំងអ្នកដែលរៀនពូកែ និងមិនសូវពូកែ។ ភាពចម្រុះនេះបានជួយឱ្យការងារជាក្រុមកាន់តែមានប្រសិទ្ធភាព ហើយគរុសិស្សអាចរៀនបានកាន់តែច្រើនពីគ្នាទៅវិញទៅមក"។*



**កុមារី គី ស្រីនិច ជាសិស្សថ្នាក់ទី៥ នៃសាលាបឋមសិក្សាសម្តេចជាស៊ីម បានលើកឡើងថា៖** *"ខ្ញុំធ្លាប់ជួបស្ថានភាពដែលគ្រូរបស់ខ្ញុំបានឱ្យក្មេងស្រីអង្គុយជាមួយក្មេងប្រុស។ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាអ្នកគ្រូរបស់ខ្ញុំឱ្យអង្គុយលាយគ្នារវាងក្មេងស្រី និងក្មេងប្រុស។ អ្នកគ្រូបានពន្យល់ថានេះជាការលើកទឹកចិត្តឱ្យមានសមភាពយេនឌ័រនៅក្នុងថ្នាក់រៀន។ ដូចនេះ ខ្ញុំមិនយល់ពីបញ្ហានេះទេ ហើយគាត់បានពន្យល់ថា សមភាពយេនឌ័រគឺជាភាពស្មើគ្នារវាងសិស្សស្រី និងសិស្សប្រុសដែលភេទទាំងពីរអាចធ្វើអ្វីមួយបានដូចគ្នា"។*

## ឯកសារណែនាំត្រូវបានបោះពុម្ពផ្សាយ

នៅក្នុងគម្រោងTIGER ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងកិច្ចការនារី បានកសាងឯកសារណែនាំដើម្បីឱ្យសាលារៀន ឆ្លើយតបនឹងសមភាពយេនឌ័រ គឺជាមជ្ឈដ្ឋានមួយដែលមានសុវត្ថិភាព និងអំណោយផលដល់ការរៀនសូត្រ សម្រាប់កុមារទាំងអស់គ្នា។

“

*ដោយសារមានការជួយគាំទ្រពីសហភាពអឺរ៉ុប និងរដ្ឋាភិបាលប៊ែលហ្ស៊ិក គម្រោងTIGER បានកសាងឯកសារណែនាំ ស្តីពីការអប់រំដែលឆ្លើយតបនឹងសមភាពយេនឌ័រ។ ការប្រើប្រាស់ឯកសារណែនាំនេះត្រូវបានគាំទ្រដោយការកសាងសមត្ថភាព ដែលក្នុងនោះក៏មានការគាំទ្រតាមរយៈការបង្វឹកផ្ទាល់ជាបន្តបន្ទាប់ផងដែរ។ បរិយាកាសរៀនសូត្រដែលឆ្លើយតបនឹងសមភាពយេនឌ័រ ដែលយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់សិស្ស និងគ្រូទាំងអស់បានរួមចំណែកលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សទាំងអស់គ្នា។*

នេះជាប្រសាសន៍របស់ **ឯកឧត្តម អ៊ុង បូរាត** នាយកខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
និងជាប្រធានក្រុមការងារត្រួតពិនិត្យការកសាងឯកសារណែនាំគម្រោង TIGER ។

ឯកសារណែនាំនេះមានពីរផ្នែកដែលមានសម្រាប់គណៈគ្រប់គ្រងសាលារៀន (មួយចំហៀង) និងសម្រាប់គ្រូបង្រៀន (ផ្នែកម្ខាងទៀត)។ ផ្នែកនីមួយៗនៃឯកសារនេះ មានជំពូកមេរៀនដែលទាក់ទងនឹងក្រុមគោលដៅនីមួយៗខាងលើ។ ផ្នែកទាំងពីរមានជំពូកសេចក្តីផ្តើមដូចគ្នា ដែលផ្តល់នូវចំណេះដឹងមូលដ្ឋានស្តីពី យេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតាមសាលារៀន។ សៀវភៅសម្រាប់ គណៈគ្រប់គ្រងសាលារៀនផ្តោតលើភាពជាអ្នកដឹកនាំសាលារៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រ និងការចូលរួមរបស់មាតាបិតា ឬសហគមន៍។ សៀវភៅសម្រាប់គ្រូបង្រៀនផ្តល់នូវគោលការណ៍ណែនាំ និងឧបករណ៍សម្រាប់អនុវត្តការបង្រៀនដែលឆ្លើយតបនឹងសមភាពយេនឌ័រទៅក្នុងថ្នាក់រៀនរបស់គាត់។



ឯកសារណែនាំនេះត្រៀមនឹងផ្សព្វផ្សាយនៅទូទាំងប្រទេស និងអាចរកមើលបានសម្រាប់ប្រើប្រាស់ក្នុងគោលបំណងមិនរកប្រាក់ចំណេញនៅលើគេហទំព័ររបស់ អង្គការ វីវីអូប៊ី (ជាភាសាខ្មែរ និងជាភាសាអង់គ្លេសក្នុងពេលឆាប់ៗនេះ)។

## ថ្លែងអំណរគុណចំពោះម្ចាស់ជំនួយ!

THIS PROJECT IS CO-FUNDED BY THE EUROPEAN UNION

Belgium
partner in development

Flanders
State of the Art

**#B-53, Borey Pea Nechakam CANADIA,
Kamakor, Svaypor, Battambang, Cambodia
Cambodia.vvob.be/tiger
Find us on Facebook: @vvobcambodia
@kapeaction, and @pkocambodia.org**

*This newsletter was produced with the financial support of the European Union and Belgium. Its contents are the sole responsibility of VVOB, KAPE, and PKO and do not necessarily reflect the view of the European Union. The Belgian and Flemish governments cannot be held responsible for its content.*